ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

♦♦♦♦♦♦

KINGDOM OF CAMBODIA
Nation Religion King

♦♦♦♦♦♦

# ទិធានមូលដ្ឋានស្តីពីដំណើរការដោះស្រាយវិវាទតាមការសម្រុះសម្រួល រវាងសហគមន៍ភូមិពូចា ភូមិពូរាំង និងក្រុមហ៊ុនសុកហ្វីន

# Ground Rules on the Process of Conflict Settlement by Mediation between Pu Char - Pu Raing Village Communities and Soc-Fin Company

វិវាទដីធ្លីរវាងសហគមន៍ភូមិពូចា និងសហគមន៍ភូមិពូរាំងជាមួយក្រុមហ៊ុនសុកហ្វីន បានកើតឡើងតាំងពីឆ្នាំ២០០៩ ដោយអូសបន្លាយរហូតមកដល់បច្ចុប្បន្ននេះនៅមិនទាន់មានដំណោះស្រាយណាមួយដែលអាចទទួលយកបានជាផ្លូវការសម្រាប់ភាគីទាំងពីរ ទើបបណ្តាលឲ្យវិវាទទាំងនេះវាបានក្លាយជាវិវាទមួយដ៏រ៉ាំរ៉ៃ ។

The land conflicts between Pu Char-Pu Raing village communities and Soc-Fin Company have dragged on since 2009 until today, and there is still no resolution acceptable to both parties, which eventually developed into a chronic conflict.

ទោះបីជាភាគីក្រុមហ៊ុន និងភាគីសហគមន៍ទទួលស្គាល់ថាធ្លាប់បានខ្នះខ្នែងព្យាយាមដោះស្រាយវិវាទរបស់ខ្លួនជាច្រើនលើកច្រើនសារមកហើយក្តី តាមរយៈគណៈកម្មាការត្រីភាគី និងកម្មវិធីផ្តល់ជាសំណងជូនដល់សហគមន៍ ប៉ុន្តែវិវាទរវាងភាគី ទាំងពីរនៅតែបន្ត និងមិនអាចដោះស្រាយបានចប់សព្វគ្រប់នៅឡើយ។

While the company and the communities recognized several attempts made to resolve their conflicts through a trilateral committee and compensation to the communities, the conflicts between the parties are ongoing and remain unsettled.

ដោយហេតុថាភាគីទាំងពីរមិនទាន់យល់នូវបញ្ហាវិវាទឲ្យបានស៊ីជម្រៅ និងជាក់លាក់នោះ ហើយចង់បានការដោះស្រាយមួយប្រកបដោយជោគជ័យ ឆាប់រហ័ស សន្តិវិធី និងរក្សាបាននូវការរាប់អានគ្នាទៅថ្ងៃអនាគតបន្តទៀតនោះ ទើបភាគីទាំងពីរធ្វើការជ្រើសរើសយកនូវការដោះស្រាយតាមរយៈការសម្រុះសម្រួលនេះឡើង។

Since the two parties have not yet understood the issue deeply and precisely and desire to seek a successful, rapid and peaceful resolution while maintaining a friendly relationship in the future, both parties chose to settle the matter by this way of mediation.

ការដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួល បានផ្តល់ឱកាសអោយភាគីទាំងពីរយល់បានច្បាស់នូវបញ្ហាវិវាទរបស់ខ្លួនជាក់លាក់ និងច្បាស់លាស់ ដោយការបង្កើតផែនទីវិវាទដែលមានការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធ ការបង្កើតជាក្រុម និងជ្រើសរើសតំណាង សម្រាប់ដោះស្រាយតាមប្រភេទវិវាទនីមួយៗរបស់សហគមន៍។ ការដោះស្រាយតាមប្រភេទវិវាទនីមួយៗនេះ វាក៏បង្កើតនៅភាពងាយស្រួលក្នុងការយល់នូវបញ្ហាបានជាក់លាក់ អាចអោយភាគីនីមួយៗចូលរួមបញ្ចេញមតិ និងលើកឡើងនៅបញ្ហារបស់ខ្លួនតាមរយៈតំណាងក្រុមនីមួយៗ។ យន្តការនេះ ក៏អាចជួយឲ្យចំណេញពេលវេលាក្នុងការប្រកបរបរចិញ្ចឹមជីវិត និងមិនប៉ះពាល់ដល់ពេលវេលារបស់ភាគីដ៏ទៃ ដែលមិនពាក់ព័ន្ធនឹងករណីវិវាទ។

ព្រះរាជាណាចក្រកម្ពុជា
ហ្គោ
GO Co., Ltd.

The resolution of conflicts through mediation provide opportunities for both parties to fully and precisely understand the issue by mapping the conflict with the participation of all parties involved, forming groups and selecting the representatives to deal with each type of conflict encountered by the communities. The resolution by each category of conflict also makes it easy to understand specific issues, by allowing each party to voice and raise their issues through the representatives of each group. This mechanism can also be time saving for livelihood and does not affect the time of the other parties involved in the case.

ភាគីសហគមន៍ភូមិពូចា ភូមិពូរាំង និងក្រុមហ៊ុនសុកហ្វីន មានបំណងចង់ឲ្យមានការស្មើភាពគ្នា និងការគោរពគ្នាទៅវិញទៅមកក្នុងការដោះស្រាយវិវាទរបស់ខ្លួន តាមរយៈការសម្រុះសម្រួល ទើបឯកភាពគ្នាបង្កើតនៅវិធានមូលដ្ឋានសម្រាប់ការសម្រុះសម្រួលនេះឡើង ដើម្បីជាបទបញ្ញាផ្ទៃក្នុងមួយសម្រាប់ភាគីទាំងពីរ ក៏ដូចជាអ្នកពាក់ព័ន្ធដទៃទៀតត្រូវធ្វើការគោរពតាមក្នុងកំឡុងពេលនៃដំណើរការសម្រុះសម្រួលវិវាទរវាងភាគីទាំងពីរ។
Pu Char & Pu Raing Village Communities and Soc-Fin Company wish for equal and mutual respect in resolving their conflicts through mediation, reaching agreement to formulate the ground rules for this mediation as internal rules for both parties as well as other relevant stakeholders to comply with during the process of conflict mediation between the two parties.

**តំណាងសហគមន៍ ភូមិពូចា ភូមិពូរាំង និងក្រុមហ៊ុនសុកហ្វីន ឯកភាពលើលក្ខខណ្ឌដូចខាងក្រោម÷**

**The community representatives of Pu Char and Pu Raing Villages and Soc-Fin Company agree on the following terms:**

**ប្រការ១. គោលបំណងនិងគោលការណ៍**

**Article 1. Purpose and Principle**

**១.១.គោលបំណង៖**

**1.1 Purpose:**

១.១.១. ចង់ស្វែងរកដំណោះស្រាយទាំងអស់គ្នា ឲ្យបានសម្រេច និងឆាប់រហ័ស។

1.1.1. Wish to find a successful and rapid resolution with which all parties are involved

១.១.២. ចង់បានទំនាក់ទំនងក្នុងនាមជាអ្នកជិតខាងនឹងគ្នា សហការគ្នា និងយោគយល់គ្នាទៅវិញទៅមក។

1.1.2. Wish to maintain a relationship as neighbors, collaboration and mutual understanding

១.១.៣. ចង់ឲ្យក្រុមហ៊ុនដោះស្រាយដីដែលពាក់ព័ន្ធ ជាមួយប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលា

1.1.3. Wish to have the company deal with the land involved with the villagers on a timely basis

១.១.៤. ចង់ឲ្យមានដំណោះស្រាយស្មើភាពគ្នារវាងក្រុមហ៊ុន និងប្រជាពលរដ្ឋឲ្យច្បាស់ សូមធ្វើដោយស្ម័គ្រចិត្ត ស្មោះត្រង់ជាមួយប្រជាពលរដ្ឋ។

1.1.4. Wish to have an equal resolution between the company and the residents, which must be made honestly with the residents.

**១.២.គោលការណ៍÷**

**1.2. Principle:**



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd. ...រាជធានីភ្នំពេញ

១.២.១. ភាគីយល់ព្រមធ្វើសកម្មភាពដោយស្មោះត្រង់ អហិង្សា គ្មានការគំរាមកំហែង គោរពគ្នាទៅវិញទៅមក មានភាពស្មើគ្នា មានប្រសិទ្ធភាពខ្ពស់ ធ្វើឡើងដោយស្ម័គ្រចិត្ត និងស្មោះត្រង់ដោះស្រាយដីធ្លី គ្មានការបង្ខិតបង្ខំ ព្រមទាំងត្រូវអនុវត្តស្របតាមច្បាប់កម្ពុជា។

1.2.1. The parties agree to act in good faith, with no violence, threat, mutual respect, equally, with high effectiveness, voluntarily and honestly in dealing with the land issue, without coercion as well as in conformity with the Cambodian laws.

១.២.២. ក្នុងកំឡុងពេលដំណើរការសម្រុះសម្រួល ដែលរៀបចំដោយអង្គការ IMG កំពុងបន្ត ភាគីណាមួយមិនអាចចូលរួមនៅក្នុងដំណើរការមួយផ្សេងទៀតស្របពេលជាមួយគ្នា ក្នុងគោលបំណងដោះស្រាយបញ្ហាដែលបានលើកឡើង នៅក្នុងពាក្យបណ្តឹងបានទេ (ហាមធ្វើការប្តឹងគ្នាទៅវិញទៅមករវាងភាគីទាំងពីរ)។

1.2.2. During the ongoing mediation process conducted by IMG, neither party may at the same time engage in any other process purported to address the issues alleged in the lawsuit (no lawsuit can be filed against each other).

**ប្រការ ២. អ្នកតំណាងតាមផ្លូវច្បាប់**

**Article 2. Legal Representative**

២.១. សហគមន៍នីមួយៗ៖

2.1. Each community:

២.១.១. អាចរើសតំណាងស្របច្បាប់០៣(បី)នាក់ ឬ០៥(ប្រាំ)នាក់ សម្រាប់ដំណើរការសន្ទានកម្ម(សម្រុះសម្រួល)នេះ

2.1.1. Can choose 03 (three) or 05 (five) legal representatives for this mediation process

២.១.២. ជ្រើសរើសតំណាងតាមក្រុមនៃវិវាទចំនួន០៣(បី)នាក់ ឬ០៥(ប្រាំ)នាក់ ក្នុងមួយក្រុមរួមមាន៖

2.1.2. Choose 03 (three) or 05 (five) representatives per group by conflict group:

- ក្រុមតំណាងសម្រាប់ករណីដីរួមសហគមន៍(ដីបម្រុងទុក, ដីព្រៃដំណាម, ដីព្រៃអារក្ស និងព្រៃកប់ខ្មោចជាដើម) ចំនួន ០៥(ប្រាំ)នាក់
- 05 (five) group representatives for the case of communal land (reserved forest land, protected forest land, spiritual forest land and burial forest, etc.)
- ក្រុមតំណាងសម្រាប់ករណីចំការពាក់ព័ន្ធដែលមិនទាន់បានដោះស្រាយ ចំនួន ០៣(បី)នាក់
- 03 (three) group representative for unsolved farmland case
- ក្រុមតំណាងសម្រាប់ករណីចំការកៅស៊ូគ្រួសារ ចំនួន ០៣(បី)នាក់
- 03 (three) group representatives for smallholder plantation case
- ក្រុមតំណាងសម្រាប់ករណីចំការ ឬដីតាមដងអូរ (គាត់ហៅថា ចំការដាក់ស្លែង) ចំនួន ០៣(បី)នាក់
- 03 (three) group representatives for farmland or riparian land (known as land practically cultivated)

២.១.៣. ចំនួនតំណាងនៃក្រុមនីមួយៗច្រើនបំផុតសម្រាប់គ្រប់ករណីមិនឲ្យលើសពី ចំនួន ០៥(ប្រាំ)នាក់។

2.1.3. The number of representatives of each group for all cases must be no more than **05 (five)**.

២.២. ភាគីក្រុមហ៊ុន អាចជ្រើសរើសអ្នកតំណាងស្របច្បាប់របស់ខ្លួនច្រើនបំផុតចំនួន ០៥(ប្រាំ) នាក់។

2.2. The company can choose its legal representative of no more than 05 (five).



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd. ចុះបញ្ជីពាណិជ្ជកម្មរាជធានីភ្នំពេញ

## ប្រការ ៣. ដំណើរការនៃកិច្ចប្រជុំ

## Article 3. Meeting Process

៣.១. ក្នុងករណីមានកិច្ចប្រជុំរួមធំៗរវាងក្រុមហ៊ុន និងសហគមន៍ទាំងមូល ភូមិនីមួយៗត្រូវធ្វើការតែងតាំងឲ្យមានវត្តមានអ្នកតំណាងស្របច្បាប់របស់ខ្លួនចំនួន០៣នាក់ ឬ ០៥(ប្រាំ)នាក់ដើម្បីចូលរួមលើដំណើរការនៃកិច្ចប្រជុំសម្រុះសម្រួលនេះ។

3.1. In the case of major meetings between the company and the community as a whole, each village has to appoint 03 (three) or 05 (five) persons as its legal representatives to attend the meeting on the process of this mediation.

៣.២. កិច្ចប្រជុំតូចៗ ឬប្រជុំដោយឡែក៖ ភាគីនឹងចាត់តាំងតំណាងស្របច្បាប់របស់ខ្លួនសម្រាប់ចូលរួមក្នុងមួយក្រុមអោយបានម្នាក់។

3.2. Small or separate meetings: The parties will assign at least one person from each group as their legal representative to participate in the meeting.

៣.៣. អ្នកតំណាងត្រូវធ្វើការប្រជុំផ្សព្វផ្សាយ អំពីព័ត៌មានផ្សេងៗនៃកិច្ចប្រជុំ ដល់សមាជិកក្រុមដែលពាក់ព័ន្ធ ឬដល់សមាជិកសហគមន៍របស់ខ្លួនដែលពាក់ព័ន្ធ។

3.3. The representatives must hold a meeting to report the meeting issues to relevant members of their groups or communities.

## ប្រការ ៤. ការធ្វើសេចក្ដីសម្រេចចិត្ត

## Article 4. Decision Making

៤.១. អ្នកតំណាងស្របច្បាប់មានសិទ្ធិសម្រេចចិត្ត និងយល់ព្រមលើបញ្ហាណាមួយ សម្រាប់សន្ទានកម្ម(សម្រុះសម្រួល)នេះក្នុងនាមខ្លួនជាអ្នកតំណាងស្របច្បាប់សម្រាប់ភូមិនីមួយៗ (ពូចា ឬពូរាំង) ឬ ជាតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

4.1. A legal representative has the right to decide and agree on any issue for this mediation in their role as legal representative for each village (Pu Char or Pu Raing) or legal representative of the company.

៤.២. នៅក្នុងកិច្ចប្រជុំសម្រុះសម្រួល អ្នកតំណាងអាចធ្វើការសម្រេចចិត្ត ដោយឈរលើការឯកភាពជារួម ពោលគឺ២នាក់ក្នុងចំណោម ៣នាក់(២/៣) ឬ៣នាក់ក្នុងចំណោម៥នាក់(៣/៥)។ ប៉ុន្តែមុននឹងការឯកភាពរបស់អ្នកតំណាងត្រូវបានចងជាកាតព្វកិច្ចព្រមព្រៀងជាមួយភាគីម្ខាងទៀត អ្នកតំណាងត្រូវសុំការគាំទ្រពីក្រុមសមាជិករបស់ខ្លួនក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃ គិតពីថ្ងៃប្រជុំឯកភាព។

4.2. In the mediation meeting, representatives can make decision based on consensus, simply, 2 out of 3 (2/3), or 3 out of 5 (3/5). However, before the approval of the representative is binding upon the other party, the representative has to seek support from his/her members within 20 (twenty) days from the meeting approved.

៤.៣. សុពលភាពនៃការអនុវត្តសេចក្ដីសម្រេចស្ថាពរ៖ ក្នុងករណីមានការផ្ទេរដី (តាមរយៈការទិញ ការជួល មរតក ឬតាមរូបភាពផ្សេងៗទៀត) សេចក្ដីសម្រេចរបស់គូភាគី នឹងត្រូវមានសុពលភាពដដែល ហើយត្រូវបានផ្ទេរបន្តទៅកាន់ម្ចាស់ដី ឬអ្នកកាន់កាប់ដីថ្មី ឬអ្នកទទួលសិទ្ធិបន្តរបស់ភាគីទាំងពីរ ឬសន្តិជន ឬអ្នកទទួលស្នងមរតកនោះ។ គូភាគីចំពោះមុខសេចក្ដីសម្រេចនេះ មានកាតព្វកិច្ចជម្រាបអ្នកទទួលសិទ្ធិបន្តអំពីកាតព្វកិច្ចក្នុងការអនុវត្តតាមសេចក្ដី

សម្រេចនេះ ហើយរាល់កំណត់ត្រាដែលពាក់ព័ន្ធ នឹងត្រូវបានភ្ជាប់ជាមួយនឹងប្លង់ដីជាឯកសារឧបសម្ព័ន្ធ។ យ៉ាងណាមិញ ក្នុងករណីដែលម្ចាស់ដីថ្មី ឬអ្នកកាន់កាប់ដីថ្មី មិនបានអនុវត្តតាមសេចក្តីសម្រេចនេះ នោះភាគីដែលបានចុះហត្ថលេខាទទួលស្គាល់សេចក្តីសម្រេច នឹងមិនត្រូវបានចងកាតព្វកិច្ចឲ្យទទួលខុសត្រូវលើករណីនេះឡើយ ប្រសិនបើខ្លួនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដូចបានចែងខាងលើ។

4.3. Binding effect of the final decision: In case the land transfer is involved (whether through the acquisition, lease, inheritance or other form), the decision of both parties will remain effective and be binding upon new owners, occupants of land or transferees of both parties, successors or heirs. The parties in making the decision are obliged to inform the transferees of the obligations to be fulfilled in compliance with the decision and all related records will be accompanied with the titles as annex. However, in case the new land owners or occupants do not comply with the decision, the parties who signed in acknowledging the decision will not be binding to be responsible for the case, if it has fulfilled its obligations as set forth above.

## ប្រការ ៥. រយៈពេលនៃដំណើរសន្ធានកម្ម (សម្រុះសម្រួល)

## Article 5. Duration of Mediation Process

៥.១. ភាគីទាំងពីរមានគោលបំណងបញ្ចប់ដំណើរការឲ្យបានត្រឹម១១(ដប់មួយ)ខែគិតចាប់ពីថ្ងៃចុះហត្ថលេខា ឬស្នាមមេដៃលើការព្រមព្រៀងចំពោះវិធានមូលដ្ឋាននេះតទៅ។

5.1. Both parties intend to conclude the process within 11 (eleven) months from the date of signature or thumb-printing on the agreement to the ground rules.

៥.២. ក្នុងករណីដែលមិនអាចដំណោះស្រាយ ក្នុងរយៈពេល ១១ (ដប់មួយ)ខែនេះ ភាគីអាចពន្យាររយៈពេលនៃការសម្រុះសម្រួលរហូតដល់ការបញ្ចប់បញ្ហា តាមកិច្ចព្រមព្រៀងរបស់គូភាគីជាលាយលក្ខណ៍អក្សរ។

5.2. In case no resolution is reached within this 11 (eleven)-month period, the parties may extend the compromise period until the issue is ended under the written agreement of the parties.

## ប្រការ ៦. ទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ ៖

## Article 6. Advisor or Consultant:

៦.១. អង្គការ និង/ ឬ មេធាវីដែលដើរតួជាទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់របស់ភាគីទាំងពីរ ត្រូវមានការទទួលស្គាល់តាមផ្លូវច្បាប់ក្នុងនាមជាមេធាវី, ឬអង្គការដែលបានចុះបញ្ជីតាមផ្លូវច្បាប់។

6.1. Organizations and/or lawyers acting as advisor or consultant of both parties must be legally recognized as a lawyer or organization registered by law.

៦.២. ទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ នឹងធ្វើការសង្កេតលើដំណើការសន្ទនា នៅក្នុងពេលសម្រុះសម្រួល និងការស្នើសុំឲ្យមានការឈប់សម្រាក ដើម្បីផ្តល់ដំបូន្មានជូនអ្នកតំណាងភាគី ទៅតាមភាពចាំបាច់។

6.2. The advisor or consultant will observe the dialogue process in the mediation and request a break to give advice to the party representatives as necessary.

៦.៣. អ្នកតំណាង/ភាគីនៅក្នុងការសម្រុះសម្រួល អាចស្នើសុំមតិយោបល់ពីទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ ទៅតាមភាពចាំបាច់។



GO Co., Ltd.

6.3. The representative/party in the mediation can seek advice from the advisor or consultant as necessary.

៦.៤. ទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ អាចផ្តល់សញ្ញាដល់អ្នកតំណាងភាគី នៅពេលដែលពួកគេមានបំណងចង់ផ្តល់មតិយោបល់។

6.4. The advisor or consultant can signal to the party representatives when they wish to comment.

៦.៥. អាចមានទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ ច្រើនបំផុត ចំនួន ០៥(ប្រាំ)នាក់។

6.5. The maximum number of advisers or consultants is five (5) persons.

៦.៦. ទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ គ្រប់រូបនឹងត្រូវបានស្នើសុំឲ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងរក្សាការសម្ងាត់មួយ។

6.6. All advisors or consultants will be asked to sign a confidentiality agreement.

**ប្រការ ៧. អ្នកសង្កេតការណ៍**

**Article 7. Observers**

៧.១. ការចូលរួមរបស់អ្នកសង្កេតការណ៍ ត្រូវមានការយល់ព្រមពីភាគីទាំងសងខាងជាមុនសិន មុនពេលអនុញ្ញាតឲ្យចូលរួមកិច្ចប្រជុំ។

7.1. The participation of observers must be approved by both parties before they are allowed to attend the meetings.

៧.២. អ្នកសង្កេតការណ៍គ្រប់រូបនឹងត្រូវបានស្នើសុំ ឲ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងរក្សាការសម្ងាត់មួយ ដែលកិច្ចព្រមព្រៀងនោះនឹងចងភាតព្វកិច្ចពួកគេ ទៅនឹងល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងវិធានមូលដ្ឋានទាំងនេះ។

7.2. All observers will be asked to sign a confidentiality agreement in which they are bound to the conditions set out in these ground rules.

៧.៣. តំណាងសហគមន៍ អាចអញ្ជើញចាស់ទុំភូមិច្រើនបំផុត០២(ពីរ)នាក់ មកធ្វើជាអ្នកសង្កេតការណ៍ក្នុងពេលចរចាបាន។

7.3. The community representatives can invite a maximum of 02 (two) village elders to be observers during the negotiation.

**ប្រការ ៨ .អាជ្ញាធររដ្ឋាភិបាល**

**Article 8. Government Authorities**

៨.១. ក្នុងករណីដែលភាគីឯកភាពគ្នាថា ការចូលរួមរបស់អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ(អាជ្ញាធរថ្នាក់ស្រុក និងឃុំ)មានភាពចាំបាច់ ភាគីអាចអញ្ជើញមន្ត្រីតំណាងរបស់ពួកគាត់ឲ្យចូលរួមដល់ដំណើរការនេះបាន ។

8.1. In case the parties agreed that the participation of relevant government authorities (district and commune authorities) is necessary, the parties can invite their representatives to join the process.

៨.២. សន្ទានការី ឬ អ្នកសម្រុះសម្រួល (IMG) នឹងបន្តជូនដំណឹងដល់អាជ្ញាធររដ្ឋាភិបាលថ្នាក់ស្រុក និងឃុំ អំពីដំណើរការតាមការឯកភាពរបស់គូភាគីទាំងសងខាង។

8.2. (IMG) mediator will continue to inform the government authorities at the commune and district levels about the process with the mutual consent of both parties.



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd.

៨.៣. មន្ត្រីអាជ្ញាធរថ្នាក់ស្រុក និងឃុំ ត្រូវបានអញ្ជើញចូលរួមក្នុងការដោះស្រាយវិវាទតាមការសម្រុះសម្រួល ក្នុងនាមជាអ្នកសង្កេតការ និងជាសាក្សី។

8.3. The commune and district authorities must be invited to participate in resolving the conflicts through the mediation as observer and witness.

**ប្រការ ៩. អ្នកសម្រុះសម្រួល ឬ សន្ធានការី**

**Article 9. Mediator**

៩.១. អង្គការ IMG នឹងរៀបចំកិច្ចប្រជុំសម្រុះសម្រួល ដោះស្រាយវិវាទរវាងភាគីសហគមន៍ និងភាគីក្រុមហ៊ុន ។

9.1. IMG will hold meetings to mediate and resolve the conflict between the communities and the company.

៩.២. អ្នកសម្រុះសម្រួលក៏អាចរៀបចំកិច្ចប្រជុំទ្វេភាគីដាច់ដោយឡែកជាមួយភាគីណាមួយ ទៅតាមភាពចាំបាច់។ ក្នុងករណីនេះ អ្នកសម្រុះសម្រួលគ្រាន់តែជូនដំណឹងទៅភាគីម្ខាងទៀតថា ខ្លួននឹងជួបប្រជុំជាមួយភាគីមួយទៀត និងពេលវេលានៃការជួបប៉ុណ្ណោះ។ អ្នកសម្រុះសម្រួលមានសិទ្ធិរក្សាទុកនូវព័ត៌មាន ដែលភាគីម្ខាងៗបានផ្តល់មកឲ្យខ្លួនជាការសម្ងាត់ ហើយអាចផ្តល់នូវការសម្ងាត់នេះទៅភាគីម្ខាងទៀតបាន លុះត្រាតែមានការឯកភាពជាលាយលក្ខណ៍អក្សរពីភាគីអ្នកផ្តល់ការសម្ងាត់នោះ។

9.2. Where necessary, the mediator may also hold separate bilateral meetings with any party. In this case, the mediator simply informs the other party that they will meet with the other party and time of the meeting. The mediator has the right to hold confidential any information made available by either party and cannot disclose the secrets to the other party unless agreed in writing by the disclosing party.

**ប្រការ ១០. ការចងក្រងឯកសារអំពីកិច្ចប្រជុំ និងការព្រមព្រៀង**

**Article 10. Documentation of Meetings and Agreements**

១០.១. កិច្ចប្រជុំនីមួយៗនឹងមានសេចក្តីសង្ខេបជាលាយលក្ខអក្សរមួយច្បាប់ ដោយភ្ជាប់នូវបញ្ជីឈ្មោះរបស់អ្នកចូលរួម និងអ្នកតំណាងទាំងអស់។

10.1. Each meeting must be accompanied with a copy of written summary and a list of all participants and representatives.

១០.២. ភាគី ឬអ្នកតំណាងនឹងត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងបណ្តោះអាសន្ន និងការព្រមព្រៀងដែលត្រូវបានសម្រេចចុងក្រោយ ដើម្បីឲ្យស្របតាម ប្រការ ៤ ចំនុច ៤.២ខាងលើ។

10.2. The parties or representatives will be required to sign an interim agreement and the final agreement in conformity with item 4.2 of Article 4 above.

១០.៣. រាល់ចំណុចដែលបានទទួលការព្រមព្រៀងគ្នារវាងគូភាគី នឹងត្រូវបានធ្វើជាកិច្ចព្រមព្រៀងជាលាយលក្ខអក្សរទុកជាភស្តុតាង។

10.3. All the issues agreed upon by the parties will form a written agreement as evidence.

**ប្រការ ១១ .បញ្ហា របៀបវារៈ និងរចនាសម្ព័ន្ធ**

**Article 11. Issue, Agenda and Structure**



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd. ចុះបញ្ជីពាណិជ្ជកម្មរាជធានីភ្នំពេញ

១១.១. បញ្ហា៖ ភាគី(តំណាងសហគមន៍ និងតំណាងក្រុមហ៊ុន) នឹងមានការព្រមព្រៀងលើបញ្ហាមួយចំនួន ដែលត្រូវលើកមកពិភាក្សាក្នុងដំណើរការសម្រុះសម្រួល។

11.1. Issues: the parties (community representatives and company representatives) will agree on some issues to be discussed during the mediation process.

១១.២. របៀបវារៈ៖ របៀបវារៈនឹងគួរតែកំណត់ជាមុនដោយអង្គការ IMG មុនពេលចាប់ផ្តើមនៃកិច្ចប្រជុំនិមួយៗ ឬចរចា។

11.2. Agenda: The agenda will be predetermined by IMG before the start of each meeting or negotiation.

១១.៣. ភាគីទាំងពីរត្រូវព្រមព្រៀងគ្នា ថា៖ ការដោះស្រាយវិវាទទៅតាមលំដាប់ពីលេខ១ដល់លេខ៤ ដូចខាងក្រោម៖

11.3. Both parties agree that: the conflict resolution will be by order from No. 1 to No. 4 as below:

1. ដីរួមសហគមន៍(ដីព្រៃបំរុង, ដីព្រៃដំណម, ដីព្រៃអារក្ស និងដីកប់ខ្មោច)

   1. Communal land (reserved forest land, protected forest land, spiritual forest land and burial forest)

2. ដីចំការ ឬដីស្រែជាក់ស្តែងតាមដងអូរ

   2. Riparian land practically cultivated or farmed

3. ដីពាក់ព័ន្ធមិនទាន់ដោះស្រាយ ឬមិនទាន់ទទួលបានសំណង

   3. Affected land which remains unsettled or not paid for compensation

4. ដីចំការកៅស៊ូគ្រួសារ

   4. Smallholder rubber plantations

១១.៤. ភាគីទាំងពីរ នឹងផ្តោតលើការសម្រុះសម្រួលវិវាទ តាមលំដាប់បញ្ហាដែលបានលើកឡើងខាងលើ។

11.4. The two parties will focus on the conflict mediation in the order of issues mentioned above.

១១.៥. ក្នុងករណីចាំបាច់ ភាគីអាចកែសម្រួលទៅលើរបៀបវារៈនោះ នៅពេលចាប់ផ្តើមកិច្ចប្រជុំនីមួយតាមការព្រមព្រៀងគ្នារបស់គូភាគី។

11.5. As necessary, the parties may adjust to the agenda at the beginning of each meeting as agreed by the parties.

១១.៦. រចនាសម្ព័ន្ធ៖ ភាគីនឹងព្រមព្រៀងលើរបៀបសម្រុះសម្រួល ដែលនឹងអនុវត្តដោយការិយាល័យ IMG។

11.6. Structure: The parties will agree on how the mediation will be conducted by the IMG Office.

**ប្រការ ១២ . ភាសាដែលប្រើសម្រាប់ដំណើរការនៃកិច្ចប្រជុំសម្រុះសម្រួល**

**Article 12. Language used for the process of mediation**

១២.១. រាល់អ្នកតំណាងគ្រប់រូប អាចនិយាយជាភាសាដើមកំណើតរបស់ខ្លួនបាន ជាភាសាពួង ភាសាខ្មែរ ឬភាសាអង់គ្លេសជាដើម។

12.1. All representatives may speak in their native language, tribal language, Khmer language or English.

១២.២. អង្គការ IMG នឹងផ្តល់ការបកប្រែភាសាសមស្រប សម្រាប់ដំណើរការសម្រុះសម្រួល។

12.2. IMG will provide appropriate interpretation for the mediation process.

ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd.

១២.៣. រាល់ឯកសារទាំងអស់ដែលប្រើប្រាស់ក្នុងការសម្រុះសម្រួល នឹងមានការបកប្រែជាពីរភាសា (ភាសាអង់គ្លេស និងភាសាខ្មែរ)។

12.3. All documents used in the mediation will be translated bilingual (English and Khmer).

**ប្រការ ១៣ .ការចំណាយនៃកិច្ចប្រជុំ**

**Article 13. Cost of Meeting**

១៣.១. អង្គការ IMG នឹងប្រើប្រាស់ថវិការបស់ម្ចាស់ជំនួយ (MRLG) ដើម្បីរ៉ាប់រងលើថ្លៃចំណាយសម្រាប់ដំណើរការនៃការសម្រុះសម្រួល ដូចជាថ្លៃបន្ទប់ប្រជុំ និងថ្លៃចំណាយដោយផ្ទាល់សមស្របដទៃទៀត ក្នុងការរៀបចំដំណើរការសម្រុះសម្រួល។

13.1. IMG will use the budget of the donor (MRLG) to cover the costs for the mediation process such as cost of meeting room and other appropriate direct expenses in the preparation of the mediation process.

១៣.២. អង្គការ IMG ក៏នឹងប្រើប្រាស់ថវិការបស់ម្ចាស់ជំនួយ (MRLG) គាំទ្រទៅលើថ្លៃចំណាយចាំបាច់ ដូចជាថ្លៃធ្វើដំណើរ ថ្លៃអាហារ និងស្នាក់នៅ សម្រាប់ភាគីសហគមន៍ និងអាជ្ញាធរមូលដ្ឋានផងដែរ។

13.2. IMG will also use donor funds (MRLG) to support required costs such as travel expenses, food, and accommodation for both the communities and the local authorities.

**ប្រការ ១៤ . ការទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ**

**Article 14. Communication and Media**

១៤.១. អ្នកតំណាងប្តេជ្ញាថា ព័ត៌មានដែលទទួលបានពីកិច្ចប្រជុំនីមួយៗនឹងត្រូវចែករំលែកឲ្យបានពេញលេញជាមួយក្រុម ដែលខ្លួនតំណាងនីមួយៗរបស់ខ្លួន តាមរយៈការប្រើប្រាស់សេចក្តីថ្លែងការណ៍រួមដែលមានការឯកភាពពីគូភាគី វិវាទ ឬសេចក្តីសម្រេចដែលមានការឯកភាពដើម្បីឲ្យអ្នកតំណាងអាចស្នើសុំការយល់ព្រមពីសមាជិកក្រុមនីមួយៗ។

14.1. The representatives agrees that the information obtained from each meeting will be fully shared with each group they represent through the use of a joint declaration to be approved by the parties to the conflict or approved decision in order that the representatives may request the consent of each group member.

១៤.២. ក្នុងករណីដែលភាគីវិវាទណាមួយ ទីប្រឹក្សា និងអ្នកសង្កេតការណ៍មានបំណងចង់ធ្វើការប្រាស្រ័យទាក់ទងទៅខាងក្រៅ អំពីដំណើរការសម្រុះសម្រួលនេះ ពួកគេអាចធ្វើទៅបាន តាមរយៈការប្រើប្រាស់សេចក្តីថ្លែងការរួមដែលភាគីវិវាទទាំងអស់បានឯកភាពគ្នា ។

14.2. In the case of any party to the conflict, advisers and observers wish to communicate to the outside the mediation process, they can do so through the use of the joint statement to which all parties have agreed.

GO Co., Ltd.

**ប្រការ ១៥. ការរក្សាការសម្ងាត់**

**Article 15. Confidentiality**

១៥.១. ខ្លឹមសារនៃកិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំ និងរាល់ឯកសារទាំងឡាយណាដែលត្រូវបានចែករំលែកក្នុងលក្ខណៈជាការសម្ងាត់ នឹងត្រូវចាត់ទុកជាព័ត៌មានសម្ងាត់និងឯករាជ្យរវាងភាគី និងមិនគប្បីចែករំលែកជាមួយសាធារណជនទូទៅ ឬប្រព័ន្ធផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតពីភាគីទាំងពីរឡើយ។

15.1. The details of discussion made in the meeting and all documents that are shared in a confidential manner will be considered confidential and independent between the parties and should not be shared with the general public or the media without the consent of the parties.

១៥.២. អ្នកតំណាងនឹងចាត់វិធានការណ៍សមស្រប ធ្វើយ៉ាងណាឲ្យសមាជិកក្រុម ឬអ្នកពាក់ព័ន្ធរបស់ពួកគាត់ បានយល់ និងគោរព និងអនុវត្តតាមបញ្ញត្តិស្តីពីការរក្សាការសម្ងាត់នេះដែរ។

15.2. Representatives will take appropriate action to ensure that their group members or stakeholders understand and comply with the confidentiality provisions.

**ប្រការ ១៦. ការអនុវត្តស្របតាមវិធានមូលដ្ឋាន**

**Article 16. Compliance with Ground Rules**

១៦.១. ភាគី (សហគមន៍ និងក្រុមហ៊ុន) អ្នកសម្រុះសម្រួល ទីប្រឹក្សា និង អ្នកសង្កេតការណ៍ យល់ព្រម និងឯកភាពអនុវត្តស្របតាមវិធានមូលដ្ឋានទាំងនេះ។

16.1. The parties (the communities and company), mediator, advisors and observers agree and approve to follow these ground rules.

១៦.២. ក្នុងករណីដែលភាគីមួយជឿថា ភាគីដទៃទៀតធ្វើខុសដោយបានរំលោភបំពានវិធានមូលដ្ឋាន ភាគីនោះត្រូវជូនដំណឹងដល់អ្នកសម្រុះសម្រួល ដើម្បីឲ្យអ្នកសម្រុះសម្រួលស្វែងរកដំណោះស្រាយចំពោះស្ថានភាពបែបនេះ។

16.2. In the event that a party believes that the other party has committed misconduct by violating the ground rules, the parties shall notify the mediator so that the mediator can find a resolution to such situation.

១៦.៣. ក្នុងករណីការសម្រុះសម្រួលមិនទទួលបានលទ្ធផល ភាគីមួយអាចជូនដំណឹងទៅភាគីម្ខាងទៀត ថាខ្លួនលែងមានបំណង ឬអារម្មណ៍បន្តការសម្រុះសម្រួល និងលែងជាប់កាតព្វកិច្ចចំពោះវិធានមូលដ្ឋានតទៅទៀតហើយ។

16.3. In the case of unfruitful mediation, either party can notify the other party that they no longer wish to or feel to pursue the mediation and to be bound by the ground rules.

**ប្រការ ១៧. ឆន្ទៈ សមត្ថភាពរបស់ភាគី និងភាសាដែលប្រើក្នុងវិធានមូលដ្ឋាន**

**Article 17. Intention, Capacity of the Parties and Language used in the Ground Rules**

១៧.១. ភាគីទាំងពីរមានឆន្ទៈរួមគ្នាបង្កើតនូវវិធានមូលដ្ឋាននេះឡើង ដោយគ្មានការបង្ខិតបង្ខំ គំនាប ឬការគម្រាមកំហែងពីភាគីណាមួយនោះឡើយ។

17.1. Both parties have common intention to adopt these ground rules without coercion or threat on the part of either party.

ព្រះរាជាណាចក្រកម្ពុជា
ហ្គោ
GO Co., Ltd.

១៧.២. ភាគីក្រុមហ៊ុនយល់ព្រមអនុញ្ញាតឲ្យមានការបកប្រែជាវិជ្ជាជីវៈ និងជាលាយលក្ខណ៍អក្សរ នូវវិធានមូលដ្ឋាននេះ ពីភាសាខ្មែរមកជាភាសាអង់គ្លេស ដើម្បីឲ្យភាគីក្រុមហ៊ុន បានយល់នូវខ្លឹមសារលម្អិតរបស់ឯកសារនេះ។

17.2. The company agrees to allow the professional translation of these ground rules in writing from Khmer to English in order for the company to understand the details of this document.

១៧.៣. ភាគីទាំងពីរបានអាន បានស្តាប់យល់ បានយល់ដឹង និងឯកភាពនូវខ្លឹមសារក្នុងគ្រប់ប្រការ នៃវិធានមូលដ្ឋាននេះ និងសន្យាថានឹងអនុវត្តគ្រប់ប្រការទាំងអស់នៃវិធានមូលដ្ឋាននេះឲ្យបានត្រឹមត្រូវ និងស្របតាមច្បាប់ ចាប់ពីពេលចុះកិច្ចព្រមព្រៀងនេះតទៅ ។

17.3. Both parties have read, been read, understood and agreed on the content in all aspects of these ground rules and undertake to conform to all these ground rules properly and in accordance with the law from the date of this agreement.

១៧.៤. វិធានមូលដ្ឋាននេះត្រូវធ្វើឡើងជាភាសាខ្មែរ និងមានការបកប្រែជាភាសាអង់គ្លេស ចំនួន ០៦ (ប្រាំមួយ)ច្បាប់ នៃភាសានីមួយៗ ហើយគ្រប់ច្បាប់ទាំងនេះត្រូវចាត់ទុកជាលិខិតតូបករណ៍តែមួយ និងដូចៗគ្នា។ ក្នុងករណីមានភាពខុសគ្នារវាងអត្ថបទជាភាសាខ្មែរ និងអត្ថបទជាភាសាអង់គ្លេស ភាសាខ្មែរត្រូវប្រើជាអត្ថបទគោលក្នុងការបកស្រាយវិធានមូលដ្ឋាននេះ។

17.4. The ground rules are made in Khmer and translated in English into 06 (six) of each language, all of which taken together shall constitute one and the same instrument. In the event of any discrepancy between the Khmer and English versions, the Khmer version contract shall be the prevailing text in interpreting these ground rules.

**ប្រការ ១៨. ការផ្លាស់ប្តូរនៅលើវិធានមូលដ្ឋាន និងប្រសិទ្ធិភាពអនុវត្ត**

**Article 18. Modification of Ground Rules and Effect**

១៨.១. ភាគីអាចធ្វើការផ្លាស់ប្តូរទៅលើវិធានមូលដ្ឋាននេះបាន លុះត្រាមានការឯកភាពជារួមពីភាគីទាំងសងខាង (សហគមន៍ និង ក្រុមហ៊ុន) ហើយការផ្លាស់ប្តូរទាំងឡាយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានការចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយគូភាគីទាំងពីរ។

18.1. The parties may not make modification to these ground rules unless with mutual approval of both parties (the communities and company), and all such modifications shall be in writing and signed or thumb-printed by the parties.

១៨.២. វិធានមូលដ្ឋាននេះនឹងត្រូវចុះហត្ថលេខាដោយ៖ គូភាគីទាំងពីរ ទីប្រឹក្សា អ្នកសង្កេតការណ៍ និង អ្នកសម្រុះសម្រួល IMG ដើម្បី ទុកជាសក្ខីភាពចំពោះមុខច្បាប់តទៅ។

18.2. These ground rules shall be signed by both parties, advisors, observers and IMG mediator as lawful proof.

១៨.៣. វិធានមូលដ្ឋាននេះនឹងមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតស្នាមមេដៃរបស់គូភាគីទាំងពីរនេះ តទៅ។

18.3. These ground rules shall be effective from the date of signing or thumb-printing by the two parties.

១៨.៤. វិធានមូលដ្ឋាននេះធ្វើឡើងជា០៦(ប្រាំមួយ)ច្បាប់ដើម ដែលមានតម្លៃស្មើគ្នា ដោយ ០២(ពីរ)ច្បាប់សម្រាប់ភាគីតំណាងសហគមន៍ (ភូមិពូចា ០១ច្បាប់ និងភូមិពូរាំង ០១ច្បាប់), ០១(មួយ)ច្បាប់ទៀតសម្រាប់ភាគីក្រុមហ៊ុន



GO Co., Ltd.

និង ០១(មួយ)ច្បាប់ តម្កល់នៅការិយាល័យ IMG, ០១(មួយ)ច្បាប់តម្កល់នៅអង្គការសហប្រជាជាតិ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និង០១(មួយ)ច្បាប់តម្កល់នៅសាលាស្រុក ពេជ្រាដា។

18.4. These ground rules are made into 06 (six) originals of equal force and effect, 02 (two) with the community representatives (01 for Pu Char village and 01 for Pu Raing village), 01 (one) with the company and 01 (one) to be filed at the IMG office, 01 (one) to be filed at the Office of the United Nations High Commissioner for Human Rights in Cambodia and 01 (one) to be filed at Pichrada District Hall, respectively.

បូស្រា,ថ្ងៃទី.13.. ខែ ...ធ្នូ...........ឆ្នាំ២០១៧

Busra, December......13......., 2017

**ហត្ថលេខា ឬស្នាមមេដៃស្តាំ**

**Signature or Right Thumbprint**

**ភាគីតំណាងសហគមន៍ភូមិពូចា**

**For Pu Char Village Community**

..............................................................................................

**ភាគីតំណាងសហគមន៍ភូមិពូរាំង**

**For Pu Raing Village Community**

..............................................................................................

..............................................................................................

GO Co., Ltd.

អ្នកសម្រុះសម្រួល
Mediator

ប៊ូច_សោភ័ណ
អង្គការសម្រុះសម្រួលឯករាជ្យ
Independent Mediation Organization (IMG)

តាងនាមក្រុមហ៊ុនសុហ្វីន
For Soc-Fin Company

[redacted]

T. Sotth ............ ថៃ សុខា

សង្កេតការណ៍
Observer

អាជ្ញាធរស្រុកពេជ្រាដា
Pichrada District Authority

អាជ្ញាធរឃុំប៊ូស្រា
Busra Commune Authority

យើត_សារិន

អង្គការសហប្រជាជាតិ
United Nations-OHCHR

[redacted]

ចាស់ទុំភូមិពូចា
Elder of Pu Char Village

ចាស់ទុំភូមិពូរាំង
Elder of Pu Riang Village

**អង្គការជាទីប្រឹក្សា ឬមេធាវីរបស់ភាគី**

**NGOs Advisors/ Attorney at Law**

| **ទីប្រឹក្សា ឬមេធាវីរបស់ភាគីសហគមន៍** | **ទីប្រឹក្សាឬមេធាវីរបស់ភាគីក្រុមហ៊ុន** |
|---|---|
| **Advisors/Attorney at Law of communities** | **Advisors/Attorney at Law of Company** |
| ............................................................ | ............................................................ |

តំណាងម្ចាស់ជំនួយ

Donor Representative

[redacted] [redacted]

ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd.